**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការ**

**ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**លេខៈ ........... គ.ទ.ក ស.ស.រ**

# បទបញ្ជាផ្ទៃក្នុង

## សំរាប់

## ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

## ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- យោងតាមព្រះរាជក្រឹត្យលេខ នស/រតក/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- យោងតាមអនុក្រឹត្យលេខ៤៦ អនក្រ-បក ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- យោងតាមសេចក្តីសំរេចលេខ ០១/០៥ គ.ទ.ក សសរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

## សម្រេច

**ប្រការ១.-**

បទបញ្ជាផ្ទៃក្នុងនេះ សំដៅកំណត់អំពីបទបញ្ជាផ្ទៃក្នុងនិងភារកិច្ចរបស់មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាដើម្បីធានាឱ្យដំណើរការវាយតម្លៃគុណភាពអប់រំ ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាពតម្លាភាពសុក្រឹត្យភាព និងមានលក្ខណៈវិជ្ជាជីវៈ ។

មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាជាមន្ត្រីមានជំនាញឯកទេសលើវិស័យអប់រំ និងវិស័យផ្សេងៗមកពីស្ថាប័នសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាលនានាទាំងក្នុង និងក្រៅប្រទេស ដែលត្រូវបានជ្រើសតាំងឡើងតាមលក្ខខណ្ឌ និងនីតិវិធីកំណត់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា។

មន្ត្រីវាយតម្លៃគុណភាពអប់រំ ដែលគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា តម្រូវឱ្យចុះវាយតម្លៃតាមគ្រឹះស្ថានឧត្តមសិក្សាណាមួយត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងដែលបានចែង។

## ប្រការ២.- មុនពេលចុះវាយតម្លៃ

**ក. ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាត្រូវអនុវត្តប្រការដូចខាងក្រោម:**

- ត្រូវយល់ដឹងអំពី ដំណើរការនៃការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សាឱ្យបានច្បាស់លាស់
- ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមមន្ត្រីវាយតម្លៃ ក្រោយពីទទួលបានការចាត់តាំងដោយ គ.ទ.ក
- ត្រូវធ្វើការសិក្សារបាយការណ៍ស្វ័យវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សាឱ្យគ្រប់ជ្រុងជ្រោយដើម្បីកំណត់នូវចំនុចខ្លាំង និងចំនុចខ្វះខាត ហើយអាចដាក់ពិន្ទុបណ្តោះអាសន្នលើសូចនាករដែលត្រូវវាយតម្លៃ
- ត្រូវរៀបចំសំណួរសំរាប់ការវាយតម្លៃ ជាពិសេសលើចំនុចខ្លាំង និង ចំនុចខ្វះខាត
- ត្រូវរៀបចំផែនការដើម្បីធានាឱ្យដំណើរការវាយតម្លៃប្រព្រឹត្តទៅតាមពេលវេលាកំណត់និងត្រូវពិនិត្យពិភាក្សាលើកម្មវិធីចុះវាយតម្លៃឱ្យបានច្បាស់លាស់
- ត្រូវរាយការណ៍ជាមុនជូនមន្ត្រីទទួលបន្ទុក អំពីគ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនមានការពាក់ព័ន្ធជាមួយដូចជា ការងារ មិត្តភាព សាច់ញាតិ (ញាតិសាលោហិត ឬញាតិព័ន្ធ) ឬក៏ធ្លាប់មានអរិភាព។

**ខ.ក្រុមមន្ត្រីវាយតម្លៃត្រូវជៀសវាងនូវប្រការដូចខាងក្រោម:**

- មិនត្រូវផ្តល់ព័តិមានណាមួយដល់គ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនត្រូវចុះវាយតម្លៃ
- មិនត្រូវសន្និដ្ឋានការវាយតម្លៃតាមរយៈរូបភាពខាងក្រៅរបស់គ្រឹះស្ថានឧត្តមសិក្សា
- មិនត្រូវមានចេតនាដើម្បីស្វែងរកប្រយោជន៍ពីគ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនត្រូវចុះវាយតម្លៃ ។

## ប្រការ៣.- ពេលចុះវាយតម្លៃ

**ក. ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាត្រូវអនុវត្តប្រការដូចខាងក្រោម:**

- ត្រូវមានភាពអព្យាក្រឹត្យ ភាពប្រាកដនិយម សុភវិនិច្ឆ័យត្រឹមត្រូវ និង តម្លាភាពក្នុងការវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ឬ ស្តង់ដារដែលកំណត់ដោយ គ.ទ.ក និងត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈ
- ត្រូវគោរពឱ្យបាននូវរយៈពេលនៃការវាយតម្លៃ។ ជៀសវាងការចំណាយពេលច្រើនទៅលើការជជែកលេងជាមួយថ្នាក់គ្រប់គ្រង មន្ត្រី បុគ្គលិកសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងពេលបំពេញភារកិច្ច

- ត្រូវមានអាកប្បកិរិយារួសរាយរាក់ទាក់ និងស្និទ្ធស្នាលជាមួយ បុគ្គលិករដ្ឋបាល បុគ្គលិកសិក្សា និងនិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងចេះលើកទឹកចិត្ត និងអំណរគុណដល់អ្នកទាំងនោះ
- ត្រូវកត់សំគាល់នូវចំណុចណាខ្លះដែលគ្រឹះស្ថានពុំបានបញ្ចូលក្នុងរបាយការណ៍ស្វ័យវាយតម្លៃ
- ត្រូវវាយតម្លៃឱ្យគ្រប់ទិដ្ឋភាពទាំងមូលដែលត្រូវវាយតម្លៃ
- ត្រូវព្យាយាមស្វែងរកការពិតរបស់គ្រឹះស្ថានឧត្តមសិក្សាឱ្យឃើញ និងប្រកបដោយភាពឈ្លៀសវៃពីការសម្ភាសន៍ និងអង្កេតជាមួយ :
    - និស្សិត
    - គ្រូបង្រៀន
    - មន្ត្រីគ្រប់គ្រង
    - សម្ភាររូបវ័ន្ត និងធនធានសិក្សា
- ត្រូវទទួលខុសត្រូវលើការដាក់ពិន្ទុលើសូចនាករនីមួយៗនិងការផ្តល់អនុសាសន៍ និងយោបល់នានាដល់គ្រឹះស្ថានឧត្តមសិក្សា និងបង្ហាញពីរបកគំហើញរបស់ខ្លួនដល់គ្រឹះស្ថានឧត្តមសិក្សា
- ត្រូវយល់ដឹងឱ្យច្បាស់ថាខ្លួន គឺជាដៃគូវាយតម្លៃ គឺជាអ្នកលើកកំពស់ និងជាអ្នកសំរបសំរួលក្នុងក្រុមខ្លួន
- ត្រូវចេះអង្កេត និងចែករំលែកនូវគំនិតរបស់ខ្លួនឱ្យបានទូលំទូលាយក្នុងក្រុម ដោយក្តីស្មោះត្រង់បំផុត
- ត្រូវប្រកាន់ខ្ជាប់នូវស្មារតី មិត្តភាពជានិច្ច ជៀសវាងបង្កើតភាពស្មុគស្មាញនិងឥរិយាបថរើសអើងក្នុងក្រុម
- ប្រសិនបើមន្ត្រីវាយតម្លៃណាម្នាក់មានគំនិតមិនយល់ស្របជាមួយនឹងសមាជិកដទៃទៀតលើការវិនិច្ឆ័យ មន្ត្រីវាយតម្លៃនោះត្រូវពន្យល់នូវគំនិតខ្លួនឱ្យបានច្បាស់ដោយផ្អែកលើលក្ខណៈវិជ្ជមាន និង អវិជ្ជមាន ហើយត្រូវឱ្យប្រធានក្រុមជាអ្នកធ្វើការសំរេចចិត្ត
- ត្រូវចងចាំថា មន្ត្រីវាយតម្លៃ គឺជាអ្នកជួយដល់គ្រឹះស្ថានឧត្តមសិក្សាឱ្យមានការអភិវឌ្ឍន៍ និងរីកចំរើន
- ត្រូវផ្លាស់ប្តូរយោបល់ទៅវិញទៅមករវាងសមាជិកក្រុមដោយសេរី
- ត្រូវទទួលនិងអនុវត្តភារកិច្ចតាមការចាត់តាំង និងការណែនាំរបស់ប្រធានក្រុម ។

**ខ.ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាត្រូវជៀសវាងនូវប្រការដូចខាងក្រោម:**

- ត្រូវជៀសវាងការវាយតម្លៃដោយប្រើនូវអគតិទាំងបួន គឺៈ ១-ឆន្ទាគតិ គឺការវាយតម្លៃលំអៀងដោយការស្រឡាញ់ ២- ទោសាគតិ គឺការវាយតម្លៃលំអៀងដោយការស្អប់ ឬខឹង ៣- មោហាគតិ គឺការវាយតម្លៃលំអៀងដោយការមិនយល់ឬល្ងង់ ៤- ភយាគតិ គឺការវាយតម្លៃលំអៀងដោយការភ័យខ្លាច
- មិនត្រូវពេញ្ចញអាកប្បកិរិយាធ្វើឱ្យភាគីខាងគ្រឹះស្ថានឧត្តមសិក្សាមានការភិតភ័យ
- មិនត្រូវបញ្ចេញលក្ខណៈភ័យខ្លាច ឬ ក៏ការប្រើអំណាចគ្របដណ្តប់
- មិនត្រូវមានចរិតកោងកាច ឬ ប្រើពាក្យពេចន៍ប្រមាថ ទោះបីមានកំហឹងក៏ដោយ

- មិនត្រូវទទួលយកអំណោយអ្វីមួយ ជាសំភារៈក្ដី ឬជាប្រាក់ក្ដី ឬក៏ការទទួលបដិសណ្ឋារកិច្ចដែលសំខាន់ពិសេសណាមួយពីគ្រឹះស្ថានឧត្ដមសិក្សា
- មិនត្រូវធ្វើការប្រៀបធៀបគ្រឹះស្ថាន ឬ ផ្នែកណាមួយរបស់គ្រឹះស្ថាននោះ ជាមួយនឹងគ្រឹះស្ថានដទៃទៀតឡើយ
- មិនត្រូវជួយ ឬ បន្ទាបគ្រឹះស្ថានឧត្ដមសិក្សាណាមួយតាមរយៈការបន្ថែម ឬ បន្ថយចំនុចខ្លាំង និងចំនុចខ្វះខាតដែលគ្រឹះស្ថានឧត្ដមសិក្សានោះមាន
- មិនត្រូវបង្វែរការពិភាក្សាការងារអោយចូលទៅក្នុងបញ្ហានយោបាយដាច់ខាត
- មិនត្រូវពិភាក្សាការងារណាមួយជាមួយគ្រឹះស្ថានឧត្ដមសិក្សាដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន
- មិនត្រូវមានការខ្វែងគំនិតឈានទៅដល់ការឈ្លោះប្រកែកគ្នា
- មិនត្រូវធ្វើជាអ្នកជួយដោះស្រាយបញ្ហា របស់គ្រឹះស្ថានឧត្ដមសិក្សាដែលផ្ទុយពីតួនាទីរបស់ខ្លួន ឬ បំលែងការចុះវាយតម្លៃទៅជាការសកម្មភាពកែច្នៃបញ្ហា
- មិនត្រូវផ្ដល់ព័ត៌មានអំពីពិន្ទុដែលមន្ត្រីវាយតម្លៃចង់ដាក់ក្នុងចិត្តដល់គ្រឹះស្ថាន និងបុគ្គលពាក់ព័ន្ធ
- មិនត្រូវបញ្ចប់ ឬ ចេញពីការងារមុនពេលដែលការវាយតម្លៃមិនទាន់បញ្ចប់
- មិនត្រូវស្នើឱ្យគ្រឹះស្ថានឧត្ដមសិក្សាទទួលខ្លួនជាគ្រូបង្រៀន ជាសមាជិកក្រុមប្រឹក្សានានា ឬស្នើសុំអ្វីមួយដែលជាប្រយោជន៍របស់ខ្លួន
- មិនត្រូវថតចម្លងឯកសារវាយតម្លៃណាមួយដែល គ.ទ.ក ផ្ដល់ជូនពេលចុះវាយតម្លៃឡើយ
- ពេលសួរសំណួរមិនត្រូវសួរជាលក្ខណៈវាយប្រហារ ឬផ្ចាញ់ផ្ចាលឡើយ
- ជៀសវាងធ្វើការរិះគន់លើរបាយការណ៍ស្វ័យវាយតម្លៃដែលរៀបចំមិនបានល្អ។ បញ្ហានេះត្រូវចែករំលែកតែក្នុងចំណោមក្រុមមន្ត្រីវាយតម្លៃតែប៉ុណ្ណោះ
- មិនត្រូវបង្ហាញការតាំងចិត្តណាមួយជំនួសក្រុមទាំងមូលដោយពុំបានពិគ្រោះយោបល់គ្នាជាមុនឡើយ
- មិនត្រូវនាំទៅជាមួយនូវញាតិមិត្ត និងគ្រួសាររបស់ខ្លួន។

## ប្រការ៤.- ក្រោយពេលចុះវាយតម្លៃ

**ក. ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្ដមសិក្សាត្រូវអនុវត្តប្រការដូចខាងក្រោម:**

- ត្រូវរៀបចំរបាយការណ៍វាយតម្លៃរៀងៗខ្លួន និងឯកសារគាំទ្រឱ្យបានតាមលំដាប់លំដោយត្រឹមត្រូវរួចបញ្ជូនទៅប្រធានក្រុមវាយតម្លៃ ឱ្យបានត្រឹមត្រូវតាមពេលវេលាដែលបានកំណត់
- ត្រូវប្រគល់ឯកសារវាយតម្លៃទាំងអស់ដែលផ្ដល់ជូនពេលចុះវាយតម្លៃ ជូនមកអគ្គលេខាធិការវិញ ។

**ខ.ក្រុមមន្ត្រីវាយតម្លៃត្រូវជៀសវាងនូវប្រការដូចខាងក្រោម:**

- មិនត្រូវទុករបាយការណ៍នៃការចុះវាយតម្លៃ ឱ្យហួសថ្ងៃចុងក្រោយនៃការចុះវាយតម្លៃឡើយ

- មិនត្រូវបង្ហាញពីរបកគំហើញ និងលទ្ធផលនៃការវាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សាដល់សាធារណៈជនឡើយ
- មិនត្រូវបង្ហាញជាសាធារណៈពីគុណសម្បត្តិ ឬ គុណវិបត្តរបស់គ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនចុះវាយតម្លៃ។

**ប្រការ៥.~ ភារកិច្ចរួមរបស់ប្រធានក្រុមវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា**

- គ្រប់គ្រង និងដឹកនាំការងាររួមរបស់ក្រុមមន្ត្រីវាយតម្លៃ
- សម្របសម្រួលការងាររវាងគ្រឹះស្ថានឧត្តមសិក្សា និងការងាររបស់ក្រុមមន្ត្រីវាយតម្លៃ ដើម្បីធានាឱ្យដំណើរការវាយតម្លៃប្រព្រឹត្តិទៅដោយរលូននិងទទួលបានជោគជ័យតាមការកំណត់
- ធានាលើដំណើរការវាយតម្លៃប្រព្រឹត្តិទៅប្រកបដោយយុត្តិធម៌ អព្យាក្រឹត្យ និង តម្លាភាព
- ចាត់តាំងសមាជិក និង មន្ត្រីជំនួយការរបស់ក្រុមមន្ត្រីវាយតម្លៃឱ្យបំពេញភារកិច្ច និងទទួលខុសត្រូវលើការងាររបស់ខ្លួន
- ទទួលខុសត្រូវលើរបាយការណ៍រួមនៃការវាយតម្លៃ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃទាំងស្រុង
- ទទួលខុសត្រូវលើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការចុះវាយតម្លៃជូនមក គ.ទ.ក តាមរយៈ អគ្គលេខាធិការដ្ឋាន នៃ គ.ទ.ក ការិយាល័យអង្កេត និងវាយតម្លៃនៃនាយកដ្ឋានស្តង់ដារ និង ការទទួលស្គាល់គុណភាពអប់រំ
- ក្នុងករណីចាំបាច់ ប្រធានក្រុមមានសិទ្ធិលើកយោបល់មកអគ្គលេខាធិការដ្ឋាន តាមរយៈនាយកដ្ឋានជំនាញនូវផលប៉ះពាល់ដល់គុណភាពអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីធ្វើសំណើរទៅ គ.ទ.ក ពិនិត្យ និងសំរេច។

**ប្រការ៦.~ ភារកិច្ចរួមរបស់មន្ត្រីជំនួយការបច្ចេកទេស**

- ទទួលនិងអនុវត្តភារកិច្ចតាមការចាត់តាំង និងការណែនាំរបស់ប្រធានក្រុម
- រៀបចំឯកសារនានាពាក់ព័ន្ធនឹងការចុះវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា សំរាប់ក្រុមមន្ត្រីវាយតម្លៃ
- តាមដាន ផ្ទៀងផ្ទាត់ និងចូលរួមយោបល់លើការពន្យល់បកស្រាយរបស់ក្រុមមន្ត្រីវាយតម្លៃដោយយកបទដ្ឋានគតិយុត្តរបស់ គ.ទ.ក ជាមូលដ្ឋាន
- ធ្វើការសម្របសម្រួលរវាងក្រុមមន្ត្រីវាយតម្លៃ និងគ្រឹះស្ថានឧត្តមសិក្សាលើដំណើរការវាយតម្លៃទាំងមូល
- ធ្វើកំណត់ហេតុអង្គប្រជុំផ្សេងៗរវាងក្រុមមន្ត្រីវាយតម្លៃ និង គ្រឹះស្ថានឧត្តមសិក្សា
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការវាយតម្លៃរបស់ក្រុមមន្ត្រីវាយតម្លៃតាមការចាត់របស់ប្រធានក្រុមមន្ត្រីវាយតម្លៃ
- គោរពតាមបទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះ

- ជួយការងារចាំបាច់ផ្សេងៗទៀតក្នុងពេលដំណើរការវាយតម្លៃ ។

**ប្រការ៧.-**

ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រី និងមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាទាំងអស់របស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។